Khmer | ខ្មែរ

# ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (DUTY OF CANDOUR)

## ប្រសិនបើអ្នកជួបប្រទះគ្រោះថ្នាក់ខ្លាំងពីសេវាកម្មសុខភាព



អ្នកជំងឺ និងគ្រួសារ ឬអ្នកថែទាំរបស់ពួកគេ មានសិទ្ធិទទួលបានការពន្យល់ និងការសុំទោសពេញលេញនៅពេលអ្នកជំងឺម្នាក់រងការឈឺចាប់ពីគ្រោះថ្នាក់ខ្លាំង ដែលត្រូវបានគេស្គាល់ថាជាព្រឹត្តិការណ៍សុវត្ថិភាពអ្នកជំងឺរងផលប៉ះពាល់ធ្ងន់ធ្ងរ (SAPSE)។ ដំណើរការបើកចំហ និងស្មោះត្រង់នេះហៅថា ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour)។

### តើអ្វីជាគ្រោះថ្នាក់ខ្លាំង?

**គ្រោះថ្នាក់ខ្លាំង គឺជាព្រឹត្តិការណ៍សុវត្ថិភាពអ្នកជំងឺរងផលប៉ះពាល់ធ្ងន់ធ្ងរ (SAPSE) ហើយជាព្រឹត្តិការណ៍មួយដែល៖**

- បានកើតឡើងខណៈពេលដែលអ្នកជំងឺកំពុងទទួលការថែទាំពីសេវាកម្មសុខភាព និង
- បាននាំមកនូវលទ្ធផលដោយអចេតនា ឬមិនបានរំពឹងទុក
  - គ្រោះថ្នាក់ដល់រាងកាយមធ្យម ឬធ្ងន់ធ្ងរ
  - គ្រោះថ្នាក់ដល់ផ្នែកចិត្តសាស្ត្ររយៈពេលយូរ
  - ការស្លាប់។

អ្នកអនុវត្តសុខភាពដែលបានចុះបញ្ជីនឹងពិនិត្យឡើងវិញលើព្រឹត្តិការណ៍នោះដើម្បីកំណត់ថាគ្រោះថ្នាក់ខ្លាំងនោះបានកើតឡើងឬអត់។

### តើករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour) មានន័យដូចម្តេចដែរនៅពេលគ្រោះថ្នាក់ខ្លាំងកើតឡើង?

**ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour) គឺជាដំណើរការមួយដែលសេវាកម្មសុខភាពនឹងផ្តល់ជូនអ្នកជំងឺ និង/ឬគ្រួសារ ឬអ្នកថែទាំរបស់ពួកគេនូវ៖**

1. ការសុំទោស
2. អង្គហេតុនៃព្រឹត្តិការណ៍
3. ការឆ្លើយតបរបស់សេវាកម្មសុខភាពទៅនឹងព្រឹត្តិការណ៍នោះ
4. ជំហាននានាដែលកំពុងត្រូវបានធ្វើឡើងដើម្បីបង្ការវាកុំឱ្យកើតឡើងម្តងទៀត។

### ប្រសិនបើអ្នកគិតថាអ្នកបានជួបប្រទះគ្រោះថ្នាក់ខ្លាំង ប៉ុន្តែសេវាកម្មសុខភាពមិនបានចាប់ផ្តើមដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour) ទេនោះ អ្នកអាចនិយាយជាមួយសេវាកម្មសុខភាពរបស់អ្នក និងស្នើសុំឱ្យពួកគេពិនិត្យឡើងវិញ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

____________________

____________________

____________________

____________________

### ដើម្បីស្វែងយល់បន្ថែមទៀតអំពីលក្ខខណ្ឌតម្រូវខាងផ្លូវច្បាប់នៃករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour)

**សូមចូលទៅកាន់៖**

www.safercare.vic.gov.au/duty-of-candour-resources-for-patients-families-and-their-carers

Safer Care Victoria